អបអរសាទរខួប

30

ឆ្នាំ

ភ្នំពេញ ប៉ុស្តិ៍

១៩៩២ - ២០២២

ភ្នំពេញ ប៉ុស្តិ៍

រាជាយការណ៍ពិសេស

ថ្ងៃសុក្រ ទី៨ ខែកក្កដា ឆ្នាំ២០២២

WWW.POSTKHMER.COM

0 19345 67894 2

សារពីអគ្គនាយក

៣ទសវត្សរ៍នៃខួបរបស់កាសែតភ្នំពេញប៉ុស្ដិ៍ និងដំណើរបន្តឆ្ពោះទៅមុខ

នៅថ្ងៃនេះកាលពី៣០ឆ្នាំមុន កាសែតភ្នំពេញប៉ុស្ដិ៍ត្រូវបានបង្កើតឡើង។ ៣ទសវត្សរ៍ក្រោយមក កាសែតមួយនេះនៅតែបន្តផ្តល់ជូនព័ត៌មានប្រកបដោយគុណភាព និងបានរួមចំណែកយ៉ាងច្រើនដល់ការកសាងសង្គមជាតិ និងជួយពង្រឹងវិជ្ជាជីវៈនៅក្នុងវិស័យមួយនេះ។

ដូចដែលយើងបានដឹងស្រាប់ហើយថា កាសែតភ្នំពេញ ប៉ុស្ដិ៍ បានខិតខំប្រឹងប្រែងតស៊ូ អត់ធ្មត់ និងក្រាញ់នៀល ក្នុងការរាយការណ៍ព័ត៌មាននៅគ្រប់កាល:ទេស: មិនថាអំឡុងពេលសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ១៩៩០ពេលមានវិបត្តិហិរញ្ញវត្ថុអាស៊ីក្នុងឆ្នាំ២០០៨ អំឡុងពេលជំងឺរាតត្បាតក្នុងរយៈពេល ២ឆ្នាំចុងក្រោយនេះនោះឡើយ។

វាគឺជាសក្ខីភាពមួយបង្ហាញអំពីគុណតម្លៃ និងគោលការណ៍ស្នូលរបស់យើង ដើម្បីធ្វើឱ្យប្រាកដថាការផ្សព្វផ្សាយពីប្រទេសជាតិនៅតែត្រូវបានធ្វើឡើង ទោះស្ថិតនៅក្នុងកាល:ទេស:ណាក៏ដោយ។ ដូច្នេះ នេះហើយជាមូលហេតុដែលយើងអាចនិយាយបានដោយមោទនភាពថា យើងនៅទីនេះដើម្បីរាយការណ៍ និងចងក្រងឯកសារអំពីសម័យកាល និងការវិវឌ្ឍរបស់ប្រទេសកម្ពុជា។ ពួកយើងរាយការណ៍ព័ត៌មានដោយមិនមានការភ័យខ្លាច ឬលម្អៀងឡើយ។

យើងបានធ្វើឱ្យប្រាកដថា រាល់ព័ត៌មានដែលយើងលើកយកមកបង្ហាញគឺជាព័ត៌មានពិតប្រាកដច្បាស់លាស់ និងគួរជាទីទុកចិត្ត ដោយមិនប្រើភាពរើរាយនៃអារម្មណ៍។ រហូតមកដល់សព្វថ្ងៃ យើងនៅតែបន្តយកចិត្តទុកដាក់ខ្ពស់ចំពោះមិត្តអ្នកអាន ដែលពឹងផ្អែកលើព័ត៌មានច្បាស់លាស់ និងមិនលម្អៀងរបស់យើង។

របាយការណ៍របស់យើងបានគ្របដណ្តប់លើព្រឹត្តិការណ៍សំខាន់ៗជាច្រើននៅកម្ពុជា ក្នុងនោះមានដូចជាគោលនយោបាយសំខាន់ៗ ការសម្រេចចិត្ត និងអនុសាសន៍របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលក៏ដូចជាធុរកិច្ច ផលប្រយោជន៍សាធារណៈ បរិស្ថាន សុខភាពសាធារណៈ:សមិទ្ធផលជាតិ សោកនាដកម្ម រហូតដល់ព័ត៌មានកីឡា និងព័ត៌មានកម្សាន្តជាច្រើនទៀត។

ផ្លាស់ប្តូរទៅតាមពេលវេលា

ខណៈ:សេដ្ឋកិច្ចបានចាប់ផ្តើមងើបឡើងវិញបន្ទាប់ពីវិបត្តិជំងឺកូវីដ១៩, ភាគច្រើននៃទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយក៏បានផ្លាស់ប្តូរទៅតាមពេលវេលាផងដែរ។ គេមិនត្រឹមតែអាចអានព័ត៌មានលើក្រដាសកាសែត បោះពុម្ពប៉ុណ្ណោះទេ ប៉ុន្តែគេក៏អាចអានបានតាមរយៈប្រព័ន្ធឌីជីថលផងដែរ ដោយសារតែសម្ទុះនៃកំណើនប្រព័ន្ធបច្ចេកវិទ្យាហើយគេអាចអានព័ត៌មានបានដោយឥតគិតថ្លៃ និងទាន់ហេតុការណ៍។ ទោះជាយ៉ាងណាក៏ដោយ ដូចអ្វីៗផ្សេងទៀតដែរ ការផ្លាស់ប្តូរនឹងមកដល់។

ភ្នំពេញប៉ុស្ដិ៍បានបន្តវិវឌ្ឍទៅតាមសម័យកាល ហើយបានស្វែងរកគ្រប់វិធីសាស្ត្រ និងមធ្យោបាយថ្មីៗ ដើម្បីផ្តល់ជូននូវព័ត៌មានឱ្យកាន់តែទូលំទូលាយ មិនថាតាមរយៈប្រព័ន្ធឌីជីថល បណ្តាញផ្សព្វផ្សាយសង្គម ឬតាមតូបលក់កាសែតនោះទេ។

យើងបន្តប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងសេរីភាពសារព័ត៌មាន និងបន្តខិតខំទាក់ទាញមិត្តអ្នកអានរបស់យើងជាមួយនឹងអត្ថបទដែលពោរពេញដោយការបំផុសគំនិត និងការយល់ដឹងស៊ីជម្រៅរាប់ចាប់តាំងពីវិស័យសាធារណៈ:ឯកជន អង្គទូត អង្គការក្រៅរដ្ឋាភិបាល ផ្នែកសិក្សាអប់រំ ដើម្បីជាវេទិកាចែករំលែកទស្សនៈរបស់ពួកគេ និងធ្វើជាកញ្ចក់ឆ្លុះនៃសង្គមជាដើម។

លោក លី តៃសេង ចាងហ្វាង និងអគ្គនាយក កាសែតភ្នំពេញ ប៉ុស្ដិ៍។

និយាយដោយស្មោះត្រង់ទៅ រយៈពេល២ឆ្នាំចុងក្រោយនេះ យើងបានប្រឈមនឹងការលំបាកជាច្រើនមិនត្រឹមតែវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រព័ន្ធផ្សព្វផ្សាយក៏ដូចគ្នាដែរ។ ប៉ុន្តែយើងបានបន្តបេសកកម្មរបស់យើងដោយប្រឈមមុខនឹងរាល់បញ្ហាលំបាកនានាក្នុងការនាំយកព័ត៌មានមកជូនអ្នកអានឱ្យបានទាន់ពេលវេលានិងគ្រប់ជ្រុងជ្រោយ យើងបានផ្តោតលើការនាំយកព័ត៌មានទៅកាន់ប្រជាជន និងរាយការណ៍ពីព្រឹត្តិការណ៍នានា ដើម្បីតាមឱ្យទាន់ពីដំណើរការផ្លាស់ប្តូររបស់ប្រទេសកម្ពុជា ក៏ដូចជាប្រជាជន ដែលប្រឈមមុខនឹងការរាតត្បាតនៃជំងឺកូវីដ១៩។

នេះបានបង្ហាញពីភាពរឹងមាំរបស់យើង ដែលនៅតែដំណើរការអស់រយៈពេល៣ទសវត្សរ៍មកនេះ ហើយសង្ឃឹមថា យើងនឹងនៅបន្តដំណើរវែងឆ្ងាយទៅមុខទៀត។

ច្បាស់លាស់, ស៊ីជម្រៅ និងឯករាជ្យ

ខណៈ:ធ្វើដំណើរឆ្ពោះទៅមុខ យើងបានសម្របខ្លួន ដើម្បីឆ្លើយតបទៅនឹងបរិបទប្រកួតប្រជែង និងទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ន ដើម្បីជានាថាអ្នកអានរបស់យើង ទទួលបាននូវរបាយការណ៍ និងព័ត៌មានពិត និងគួរឱ្យទុកចិត្ត។

ការផ្តល់ព័ត៌មានត្រូវបានពង្រីកទៅកាន់វេទិកាឌីជីថល ដើម្បីតាមឱ្យទាន់ការវិវឌ្ឍនាពេលបច្ចុប្បន្ន ខណៈ:គេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់យើង ដូចជា Facebook, Twitter, LinkedIn, Instagram និង Telegram ផ្តល់ឱ្យអ្នកអានជាប្រចាំអំពីព័ត៌មានទាន់ហេតុការណ៍ដ៏សម្បូរបែបទាន់ហេតុការណ៍បច្ចុប្បន្ន ក៏ដូចជាពិភពព័ត៌មានអាជីវកម្ម។

បច្ចុប្បន្នយើងមានអ្នកមើលនិងគាំទ្រជាង៩លាននាក់នៅលើគេហទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គម ក្នុងនោះជាង៧លាននាក់នៅលើfacebook ដែលធ្វើឱ្យយើងក្លាយជាប្រព័ន្ធផ្សព្វផ្សាយមួយក្នុងចំណោមកាសែតបោះពុម្ពផ្សាយជាខេមរភាសា និងភាសាអង់គ្លេស ដែលមានគេមើលច្រើនបំផុតនៅក្នុងវេទិកាឌីជីថលកម្ពុជា។

ដោយមើលឃើញពីចំនួនដ៏ច្រើននេះ យើងសង្ឃឹមថា នឹងបន្តវិវឌ្ឍដើម្បីបម្រើមិត្តអ្នកអានរបស់យើង និងរក្សាឈ្មោះជា«កាសែតរបស់ប្រជាជន»ឱ្យបានយូរអង្វែង ដូចដែលយើងមានកាលពីអតីតកាល។

ដូច្នេះយើងសន្យានឹងបន្តបំពេញកាតព្វកិច្ចរបស់យើងក្នុងនាមជាអ្នកសារព័ត៌មានដើម្បីនាំយកព័ត៌មានច្បាស់លាស់ ស៊ីជម្រៅ និងឯករាជ្យជូនប្រទេសជាតិ តាមបាវចនារបស់យើង។

ថ្លែងអំណរគុណ និងដឹងគុណ

ផ្លូវខាងមុខគឺមិនប្រាកដប្រជានោះទេ។ ពេលវេលាកំពុងផ្លាស់ប្តូរ ហើយយើងក៏ត្រូវតែផ្លាស់ប្តូរទៅតាមនោះដែរ ប៉ុន្តែរឿងមួយដែលស្ថិតស្ថេរជានិច្ច គឺអ្នកអានរបស់យើង។ ដូច្នេះយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមិត្តអ្នកអានដែលតែងតែនៅជាមួយយើង និងធ្វើឱ្យយើងមានអាយុកាលរហូតដល់៣០ឆ្នាំនេះ។

យើងខ្ញុំជាថ្នាក់ដឹកនាំ និងបុគ្គលិកកាសែតភ្នំពេញប៉ុស្ដិ៍ទាំងអស់សូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងព័ត៌មាន ដែលបានសម្រួលដល់យើងខ្ញុំដើម្បីប្រតិបត្តិការផ្សព្វផ្សាយប្រកបដោយសុវត្ថិភាព វិជ្ជាជីវៈ និងឯករាជ្យ។

ទន្ទឹមនឹងនេះ យើងក៏សូមអរគុណចំពោះក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម និងដៃគូអាជីវកម្មរបស់យើងទាំងអស់ ចំពោះការគាំទ្រ ការសហការ និងទំនុកចិត្តមកលើផលិតផលរបស់យើង។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលិក ទាំងបុគ្គលិកពីអតីតកាល និងបច្ចុប្បន្នគ្រប់ផ្នែកទាំងអស់ ចំពោះកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរបំពេញភារកិច្ចនាពេលកន្លងមកក៏ដូចជាស្វែងរកព័ត៌មានសម្បូរបែប ដើម្បីធ្វើឱ្យកាសែតរបស់យើងមានអាយុកាលជាច្រើនឆ្នាំមកនេះ។ កាសែតភ្នំពេញប៉ុស្ដិ៍នឹងមិនអាចសម្រេចបាននូវអ្វីដូចយើងមានពេលបច្ចុប្បន្ននេះទេ ប្រសិនបើគ្មានការចូលរួមពីអ្នកទាំងអស់គ្នា។

ដូច្នេះ នៅក្នុងឱកាសដ៏វិសេសវិសាលនៃការប្រារព្ធខួបរបស់កាសែតភ្នំពេញប៉ុស្ដិ៍នេះ យើងខ្ញុំពិតជាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដែលធ្វើឱ្យយើងធ្វើដំណើរមកដល់ពេលនេះ។ ទោះបីអនាគតមិនច្បាស់លាស់ក្តីក៏យើងនៅតែសង្ឃឹមថា អ្នកទាំងអស់គ្នានឹងនៅតែបន្តនៅជាមួយយើង ខណៈ:យើងកំពុងធ្វើដំណើរឆ្ពោះទៅមុខ។

ខ្ញុំសូមជូនពរអ្នកទាំងអស់គ្នាសូមឱ្យទទួលបានជោគជ័យគ្រប់ភារកិច្ច!

សូមអបអរសាទរខួបគម្រប់៣០ឆ្នាំរបស់កាសែតភ្នំពេញប៉ុស្ដិ៍!

ចំណាប់អារម្មណ៍ពីមជ្ឈដ្ឋាននានាជុំវិញដំណើរការកាសែតភ្នំពេញប៉ុស្ដិ៍រយៈពេល៣០ឆ្នាំ

មុំ គន្ធា និងនៅ ស៊ីវុត្ថា

ភ្នំពេញ៖សារព័ត៌មានភ្នំពេញ-ប៉ុស្ដិ៍គឺជាស្ថាប័នផ្សព្វផ្សាយឯករាជ្យមួយនៅកម្ពុជា ដែលមានវ័យ៣០ឆ្នាំមកហើយ ដែលកាសែតនេះនៅតែបន្តប្រកាន់ខ្ជាប់នូវគោលការណ៍ស្នូលដើម្បីនាំមកនូវព័ត៌មានប្រកបដោយគុណភាពដល់មិត្តអ្នកអានទាំងខ្មែរ និងបរទេស និងបានរួមចំណែកក្នុងវិជ្ជាជីវៈដល់ការកសាងប្រទេសជាតិ ជាអ្វីដែលស្ថាប័នមួយនេះបានខិតខំប្រឹងប្រែងកន្លងមកនេះ។

ប្រជាពលរដ្ឋអានកាសែតភ្នំពេញប៉ុស្ដិ៍។ រូបថត ហេង ជីវ័ន

ក្នុងខួប៣០ឆ្នាំនេះដែរ មន្ត្រីជាន់ខ្ពស់ក្នុងជួររាជរដ្ឋាភិបាល អ្នកនយោបាយអ្នកវិភាគសង្គមសេដ្ឋកិច្ច រួមនឹងសាស្ត្រាចារ្យផ្នែកសារព័ត៌មានបានផ្តល់នូវចំណាប់អារម្មណ៍ផ្ទាល់ខ្លួនពីដំណើរការនៃកាសែតភ្នំពេញប៉ុស្ដិ៍តាំងពីដំបូងរហូតមកដល់បច្ចុប្បន្ននេះដែលមានខ្លឹមសារដូចខាងក្រោម៖

លោកជិន ម៉ាលីន រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងយុត្តិធម៌៖កាសែតភ្នំពេញប៉ុស្ដិ៍ជាកាសែតមួយប្រកបដោយវិជ្ជាជីវៈដែលបានដើរតួនាទីសំខាន់ក្នុងការផ្សព្វផ្សាយនូវព័ត៌មានក៏ដូចជាចំណេះដឹងជូនដល់សាធារណជនបានច្រើន និងមានប្រយោជន៍ដល់សង្គមជាតិ។ជាពិសេសកាសែតនេះបានផ្សាយព័ត៌មានជា២ភាសា គឺភាសាខ្មែរ និងអង់គ្លេស ហើយវាក៏ជាកាសែតមួយដែលមានទំនាក់ទំនងល្អជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ មានន័យថា កាសែតភ្នំពេញប៉ុស្ដិ៍អាចធ្វើការ និងមានកិច្ចសហការពីគ្រប់ភាគីពាក់ព័ន្ធក្នុងការបញ្ជូននូវព័ត៌មានពិត ព័ត៌មានប្រកបដោយវិជ្ជាជីវៈក៏ដូចជាការចែករំលែកនូវចំណេះដឹងផ្សេងៗដែលមានសារប្រយោជន៍ដល់សង្គមជាតិ។

លោកថា៖«ខ្ញុំសូមលើកទឹកចិត្តឱ្យបន្តនូវសកម្មភាពការផ្សព្វផ្សាយព័ត៌មានការចែករំលែកចំណេះដឹងប្រកបដោយវិជ្ជាជីវៈនេះបន្តទៀតដើម្បីជាប្រយោជន៍ដល់សង្គមជាតិ និងប្រជាពលរដ្ឋរបស់យើង»។

រីឯលោកប៉ា ចន្ថរឿន ប្រធានវិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា៖ សម្រាប់ខ្ញុំផ្ទាល់ កាសែតភ្នំពេញប៉ុស្ដិ៍ដែលមានទាំងភាសាខ្មែរ និងភាសាអង់គ្លេសជាស្ថាប័នសារព័ត៌មានមួយដែលមានវ័យចំណាស់ក្នុងចំណោមសារព័ត៌មានមួយចំនួនដែលបានបង្កើតឡើងតាំងពីកំណើតទី២នៃព្រះរាជាណាចក្រកម្ពុជាក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស និងការបោះឆ្នោតដែលរៀបចំដោយអ៊ុនតាក់ឆ្នាំ១៩៩៣។

លោកថា៖«ខ្ញុំមើលឃើញថា កាសែតភ្នំពេញប៉ុស្ដិ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ដំណើរការប្រជាធិបតេយ្យ ជាពិសេសការផ្តល់នូវព័ត៌មានត្រឹមត្រូវដែលអាចយកជាការបាន ពីព្រោះក្នុងសង្គមប្រជាធិបតេយ្យ ព័ត៌មានមានសារៈសំខាន់ណាស់។ខ្ញុំនៅតែជឿថា សារព័ត៌មានភ្នំពេញប៉ុស្ដិ៍នៅតែមានតួនាទីដ៏សំខាន់ក្នុងការជួយឱ្យដំណើរការប្រជាធិបតេយ្យនៅកម្ពុជាមានភាពកាន់តែល្អប្រសើរ»។

លោកបន្ថែមថា៖«ទោះបីជាស្ថានភាពសេរីភាពសារព័ត៌មាននៅកម្ពុជាមានការធ្លាក់ចុះជាបន្តបន្ទាប់ប៉ុន្មានឆ្នាំមកក្តី តែកាសែតភ្នំពេញប៉ុស្ដិ៍នៅប្រកាន់ជំហរអព្យាក្រឹត ឯករាជ្យ និងអត្ថបទមានប្រភពចម្រុះទាំងគណបក្សកាន់អំណាច គណបក្សប្រឆាំង អង្គការសង្គមស៊ីវិល ទាំងវិស័យឯកជន»។

ចំណែកលោក ឆាយ សុផល សាស្ត្រាចារ្យផ្នែកសារព័ត៌មាន និងជាអ្នកនិពន្ធសៀវភៅ មើលឃើញថា កាសែតភ្នំពេញប៉ុស្ដិ៍គឺជាកាសែតមួយដែលមានអាជីពវិជ្ជាជីវៈក្នុងការងាររបស់ខ្លួនតាំងពីយូរមកហើយ ហើយជាសារព័ត៌មានមួយមាន២ភាសា និងដែលអាចនៅបន្តបោះពុម្ពរហូតមកទល់សព្វថ្ងៃ ខណៈដែលកាសែតក្នុងស្រុកដទៃទៀតភាគច្រើនលែងបោះពុម្ពហើយ។ ដូច្នេះកាសែតភ្នំពេញប៉ុស្ដិ៍នៅតែក្រាញនៀល ស្ងិតស្ងាញ ធ្វើការបោះពុម្ព ហើយក្នុងនោះក៏មានអនឡាញផងដែរ។

លោកបញ្ជាក់ថា៖«ខ្ញុំអានកាសែតភ្នំពេញប៉ុស្ដិ៍ហើយក៏ធ្លាប់យកអត្ថបទខ្លះ ធ្វើជាគន្លឹះទ្វេជាឯកសារយោងផងដែរ។ ខ្ញុំសូមលើកទឹកចិត្តឱ្យស្ថាប័នកាសែតភ្នំពេញប៉ុស្ដិ៍ បន្ត និងលើកទឹកចិត្តឱ្យអ្នកសារព័ត៌មានរបស់យើងខិតខំប្រឹងប្រែងបន្តកិច្ចការងារក្នុងបេសកកម្មសេរីភាពសារព័ត៌មានក្នុងប្រទេសកម្ពុជា»។

លោក ផៃ ស៊ីផាន អ្នកនាំពាក្យរាជរដ្ឋាភិបាលកម្ពុជាថ្លែងថា៖ ខ្ញុំមើលឃើញថា ការផ្តល់សេវាកម្មផ្នែកព័ត៌មានល្អ ក្នុងន័យជាសារព័ត៌មានអង់គ្លេសដែលជាការរួមចំណែកមួយដ៏ធំ ហើយខ្ញុំឃើញមានការយកចិត្តទុកដាក់ និងយក(ប្រភព)ពីកាសែតភ្នំពេញប៉ុស្ដិ៍ច្រើនទៅប្រើប្រាស់ទូទាំងពិភពលោក។

ក្នុងនាមជាអ្នកនាំពាក្យរាជរដ្ឋាភិបាល «យើងសូមថ្លែងអំណរគុណចំពោះការខិតខំប្រឹងប្រែងប្រកបដោយវិជ្ជាជីវៈរបស់កាសែតភ្នំពេញប៉ុស្ដិ៍ហើយ ខ្ញុំតាមមើលជារៀងរាល់ពេលផងដែរ។ចំណែកការរាយការណ៍គឺអាចទទួលយកបាន ការរាយការណ៍ប្រកបដោយវិជ្ជាជីវៈមិនមានការខ្វះចន្លោះនោះទេ»។

លោក គី សិរីវឌ្ឍ អ្នកស្រាវជ្រាវសេដ្ឋកិច្ចនៃរាជបណ្ឌិត្យសភាកម្ពុជា៖ ខ្ញុំចូលចិត្តអានស្តាប់ និងតាមដានព័ត៌មានដើម្បីស្វែងរកព័ត៌មានបានទទួលនូវចំណេះដឹងទូទៅបន្ថែម និងជារឿងជាក់ស្តែងមួយនៅក្នុងប្រទេសសម្រាប់ធ្វើការសម្រេចចិត្ត សម្រាប់ឱ្យយើងរៀបចំយុទ្ធសាស្ត្រ និងតាក់ទិចក្នុងការអនុវត្តការងារ។

លោកថា៖ «ខ្ញុំយល់ថាកាសែតភ្នំពេញប៉ុស្ដិ៍ជាកាសែតមួយដែលបានសរសេរនូវរឿងរ៉ាវដែលមានភាពពិតច្រើន ហើយបានយកគំនិតរបស់អ្នកស្រាវជ្រាវទៅផ្សព្វផ្សាយដើម្បីជូនប្រជាពលរដ្ឋឱ្យបានជ្រាប បានដឹង ហើយការជ្រើសរើសអ្នកដែលផ្តល់បទសម្ភាសមិនលម្អៀងដោយបានជ្រើសរើសប្រភពជាអ្នកដែលមាននិន្នាការឯករាជ្យនៅក្នុងការវិភាគនៅក្នុងការផ្តល់បទសម្ភាសជាជាងការសម្ភាសទៅលើអ្នកដែលមានការឆ្មៀងឬលម្អៀងទៅខាងគាំទ្ររដ្ឋាភិបាល ឬប្រឆាំងរដ្ឋាភិបាល។

លោក មាស សុភ័ណ្ឌ អនុរដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងព័ត៌មាន៖ ខ្ញុំសូមចូលរួមអបអរសាទរចំពោះខួប៣០ឆ្នាំនៃការបង្កើតអង្គភាពសារព័ត៌មានភ្នំពេញប៉ុស្ដិ៍ និងសូមជូនពរឱ្យអង្គភាពសារព័ត៌មានភ្នំពេញប៉ុស្ដិ៍កាន់តែរីកចម្រើន និងទទួលបានជោគជ័យថ្មីៗបន្ថែមទៀត។

លោកលើកឡើងថា នៅកម្ពុជាសារព័ត៌មាន បាននិងកំពុងបំពេញតួនាទីភារកិច្ចយ៉ាងសំខាន់ និងយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានជូនដល់ប្រជាជនកម្ពុជានៅគ្រប់ទិសទីទាំងក្នុង និងក្រៅប្រទេស។ ក្នុងនោះសារព័ត៌មានភ្នំពេញប៉ុស្ដិ៍ក៏ជាអង្គភាពសារព័ត៌មានមួយដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងការផ្សព្វផ្សាយព័ត៌មានពិត និងប្រកបដោយវិជ្ជាជីវៈផងដែរ។

លោកថ្លែងថា៖«អង្គភាពសារព័ត៌មាននេះក៏អាចនិយាយបានថាជាអង្គភាពសារព័ត៌មានដ៏ចំណាស់ និងពោរពេញទៅដោយបទពិសោធមួយក្នុងការលើកស្ទួយវិជ្ជាជីវៈសារព័ត៌មាននៅកម្ពុជា និងក៏បានចូលរួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មានដល់អ្នកសារព័ត៌មានមួយចំនួននៅកម្ពុជាផងដែរ»។

ចំណែកលោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិត្យសភាកម្ពុជាបានលើកឡើងថា ភ្នំពេញប៉ុស្ដិ៍បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ព័ត៌មាន និងជាភ្នាក់ងារនាំបញ្ហាសង្គម នយោបាយ និងសេដ្ឋកិច្ចជូនប្រជាពលរដ្ឋខ្មែរប្រកបដោយវិជ្ជាជីវៈ ដែលធ្វើឱ្យប្រជាពលរដ្ឋមានមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្តបានត្រឹមត្រូវតាមរយៈព័ត៌មានពីកាសែតនេះ។

លោកថ្លែងថា៖«ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះ ប្រជាពលរដ្ឋទទួលបានព័ត៌មានច្រើនសូម្បីតែក្នុងការស្រាវជ្រាវរបស់ខ្ញុំ ទិន្នន័យព័ត៌មានមួយចំនួនក៏ខ្ញុំទទួលបានពីភ្នំពេញប៉ុស្ដិ៍ដែរ ខ្ញុំយោងបានច្រើនដោយសារភ្នំពេញប៉ុស្ដិ៍មានវិស័យច្រើន»។

ចំពោះលោក សុខ ឥសាន អ្នកនាំពាក្យគណបក្សប្រជាជនកម្ពុជាវិញ បានឱ្យដឹងដែរថា កាសែតភ្នំពេញប៉ុស្ដិ៍ បើប្រៀបធៀបជាមួយសារព័ត៌មានផ្សេងទៀត ជាពិសេសប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិក ឃើញថាមានលក្ខណៈប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈល្អបង្គួរសម្រាប់ជាទីទុកចិត្តដល់មហាជនក្នុងការទទួលបានព័ត៌មាន។

លោកថ្លែងថា៖«ខ្ញុំយល់ថាភាគច្រើន ភ្នំពេញប៉ុស្ដិ៍និយាយពិត និយាយត្រង់ច្រើន មិនមានការបំផ្លើស មិនមានការពង្រីកឬបំប៉ោងឬមួយប្រឌិតព័ត៌មានអីទេ។នេះខ្ញុំនិយាយដោយសុទ្ធចិត្តពីព្រោះភ្នំពេញប៉ុស្ដិ៍មិនដែលសូកប៉ាន់អីខ្ញុំទេ។ក្នុងនាមយើងជាអ្នកព័ត៌មានយើងមិនបាច់អួតខ្លួនឯងថាល្អ និងមានវិជ្ជាជីវៈ និងក្រមសីលធម៌អីទេបញ្ហាសំខាន់គឺខ្លឹមសារអត្ថបទរបស់យើងដែលផ្សាយទៅផ្សារភ្ជាប់នឹងការពិតជាក់ស្តែងព្រឹត្តិការណ៍ដែលកើតឡើងដែរ ឬទេ»។

លោកបន្តថា៖«បើយើងមិនផ្សារភ្ជាប់នូវព្រឹត្តិការណ៍ដែលកើតឡើងណាមួយទេ ហើយយើងទៅស្រែកថា យើងមានក្រមសីលធម៌ អាហ្នឹង ក៏គ្មានអ្នកណាជឿដែរ ហើយវាបាត់បង់កិត្តិយស និងសេចក្តីថ្លៃថ្នូរក៏ដូចជាកេរ្តិ៍ឈ្មោះរបស់កាសែតយើងដែរ។ខ្ញុំយល់ថា ដើម្បីឱ្យមហាជន និងប្រជាជនមានការទុកចិត្តមានតែប្រកាន់ខ្ជាប់នូវក្រមសីលធម៌ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ហើយសារសេរព័ត៌មានមកតាមព្រឹត្តិការណ៍ដែលកើតឡើង យើងកុំប្រឌិតអាហ្នឹងអត់មានបញ្ហាអីទេ»។

លោក ថាច់ សេដ្ឋា អនុប្រធានគណបក្សភ្លើងទៀនក៏បានលើកឡើងដែរថា លោកបានគាំទ្រកាសែតភ្នំពេញប៉ុស្ដិ៍តាំងពីដើមរៀងមក។

លោកថ្លែងថា៖«ពីមុនយើងឃើញព័ត៌មានទាំងអស់ដែលភ្នំពេញប៉ុស្ដិ៍ចុះផ្សាយ យើងទុកចិត្ត និងយកជាការបាន ព្រោះមានមូលដ្ឋានគ្រប់គ្រាន់ និងមានវិជ្ជាជីវៈត្រឹមត្រូវដោយមិនគិតពីនិន្នាការនយោបាយ»។

ជាមួយគ្នានេះលោកបានស្នើឱ្យកាសែតភ្នំពេញប៉ុស្ដិ៍បន្តចុះផ្សាយនូវព័ត៌មានពិត និងមិនលម្អៀងប្រកបដោយវិជ្ជាជីវៈក្នុងការផ្តល់ឱ្យប្រជាពលរដ្ឋ និងអ្នកនយោបាយក្នុងការសម្រេចចិត្ត និងប្រើប្រាស់ជាមូលដ្ឋានផ្សេងឱ្យបានត្រឹមត្រូវ។

ដោយឡែកលោក ឡឹក សុធារ អ្នកនាំពាក្យគណបក្សប្រជាធិបតេយ្យមូលដ្ឋានបានកោតសរសើរកាសែតភ្នំពេញប៉ុស្ដិ៍ដែលបានបង្ហាញនូវជំហរអព្យាក្រឹត និងវិជ្ជាជីវៈខ្ពស់ដែលមិនលម្អៀងទៅគណបក្សនយោបាយណាមួយ ហើយតែងតែប្រើប្រាស់ព័ត៌មានគ្រប់ប្រភព និងគ្រប់ជ្រុងជ្រោយដើម្បីផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ។

លោកថ្លែងថា៖«ខ្ញុំពិតជារីករាយ ខ្ញុំគិតថាវត្តមានរបស់កាសែតភ្នំពេញប៉ុស្ដិ៍នៅកម្ពុជាគឺជួយបានយ៉ាងធំធេងទៅដល់ការកសាងនូវលទ្ធិប្រជាធិបតេយ្យ និងសេរីភាពក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងសិទ្ធិទទួលបានព័ត៌មានផងដែរ»។

រីឯលោក អំ សំអាត នាយករងអង្គការលីកាដូបានថ្លែងថា កាសែតភ្នំពេញប៉ុស្ដិ៍ដើរតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកព័ត៌មានទៅប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ។ ទោះបីជាមានការផ្លាស់ប្តូរថ្នាក់ដឹកនាំក្រុមហ៊ុនក៏ដោយ ក៏ប៉ុន្តែភ្នំពេញប៉ុស្ដិ៍នៅតែដើរតួនាទីដ៏សំខាន់ក្នុងនាមកាសែតអន្តរជាតិក្នុងស្រុក។

លោកថា៖ «ព័ត៌មានភ្នំពេញប៉ុស្ដិ៍ ខ្ញុំឃើញថា គេចូលចិត្តមើលច្រើន ហើយបើនិយាយពីមុនមកគេចាត់ទុកថា កាសែតភ្នំពេញប៉ុស្ដិ៍នេះ ជាកាសែតឯករាជ្យ ប៉ុន្តែបន្ទាប់ពីមានការផ្លាស់ប្តូរក្រុមហ៊ុនមកក៏ទទួលរងនូវការរិះគន់ខ្លះ ប៉ុន្តែយ៉ាងណាក៏ដោយ ភ្នំពេញប៉ុស្ដិ៍នៅតែដើរតួនាទីសំខាន់ដែរសម្រាប់សារព័ត៌មានអន្តរជាតិក្នុងស្រុក»។

លោក ឯម សុវណ្ណារ៉ា អ្នកវិភាគ និងអ្នកតាមដានបញ្ហានយោបាយនៅកម្ពុជាបានឱ្យដឹងដែរថា លោកគឺជាអ្នកតាមដានសារព័ត៌មានជាពិសេសឧស្សាហ៍អានព័ត៌មានពីកាសែតភ្នំពេញប៉ុស្ដិ៍ដើម្បីជាមូលដ្ឋានក្នុងការវិភាគ និងក៏ដូចជាស្រាវជ្រាវព្រោះកាសែតនេះផ្តល់នូវព័ត៌មានពិត និងគ្រប់ជ្រុងជ្រោយ៕ ■

អ្នកហាត់ការនៅភ្នំពេញប៉ុស្ដិ៍បង្ហាញភាពជោគជ័យរបស់ពួកគេ

មុំ គន្ធា

ភ្នំពេញ: ជាស្ថាប័នសារព័ត៌មាន-ឯកសារាជ្យមួយក្នុងប្រទេសកម្ពុជាដែលត្រូវបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ ១៩៩២ ដែលមកទល់ពេលនេះ ភ្នំពេញប៉ុស្ដិ៍ មានអាយុ ៣០ឆ្នាំគត់ ដែលមានភាសាអង់គ្លេស និងភាសាខ្មែរបោះពុម្ពតាមក្រោយក្នុងអំឡុងឆ្នាំ ២០០៩ និងត្រូវបានប្រជាពលរដ្ឋជាច្រើនស្គាល់។

ក្រៅពីផ្តល់ព័ត៌មានប្រកបដោយវិជ្ជាជីវៈ និងឯកសារាជ្យ ភ្នំពេញប៉ុស្ដិ៍ក៏ជាកន្លែងបណ្តុះបណ្តាលមួយផងដែរ ដែលបានកំពុងតែផ្តល់ឱកាសដល់យុវជន សិស្សនិស្សិតដែលចង់ស្វែងយល់ពីការងារសារព័ត៌មាននេះ ដើម្បីអនុវត្តការងារផ្នែក ក៏ដូចជារៀនសូត្រយកបទពិសោធពីអ្នកយកព័ត៌មានភ្នំពេញប៉ុស្ដិ៍អាជីពផងដែរ។

លោក រ៉ូ គឹមឡុង និស្សិតនៃដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍(DMC) នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានចំណាយពេលវេលារបស់លោករយៈពេល៦ខែ នាឆ្នាំ ២០២១កន្លងទៅនេះ មកធ្វើជាអ្នកហាត់ការនៅកាសែតភ្នំពេញប៉ុស្ដិ៍។

លោកបានប្រាប់ភ្នំពេញប៉ុស្ដិ៍ថា លោកមានចំណាប់អារម្មណ៍មកហាត់ការនៅកាសែតភ្នំពេញប៉ុស្ដិ៍ ដោយសារស្ថាប័ននេះជាស្ថាប័នកាសែតដ៏មានវ័យចំណាស់មួយដែលមានបទពិសោធរាប់ទសវត្សរ៍ លើការរាយការណ៍ព្រឹត្តិការណ៍នានាទាំងក្នុង និងក្រៅប្រទេស និងព័ត៌មានជាច្រើនប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈដែលមានការផ្សៀងផ្ទាត់ព័ត៌មានច្បាស់លាស់ពីប្រភពពាក់ព័ន្ធ ហើយក៏មានសារៈសំខាន់ដល់សង្គមកម្ពុជា និងអ្នកអានគ្រប់វ័យផងដែរ។

លោក គឹមឡុង ថ្លែងថា៖ «ម៉្យាងវិញទៀត ខ្ញុំគិតថា នៅពេលបច្ចុប្បន្ននេះ មានស្ថាប័នសារព័ត៌មានតិចណាស់ដែលផលិត និងចេញផ្សាយអត្ថបទរបស់ខ្លួនត្រឹមត្រូវគ្រប់ជ្រុងជ្រោយតាមសីលធម៌ក្រមវិជ្ជាជីវៈ ហើយនេះក៏ជាកត្តាជំរុញឱ្យខ្ញុំមកហាត់ការនៅទីនេះ ដោយសារតម្លៃនៃការងាររបស់អត្ថបទចេញផ្សាយរបស់ស្ថាប័នភ្នំពេញប៉ុស្ដិ៍»។

ក្នុងរយៈពេល ៦ខែ ដែលលោកបានហាត់ការនៅផ្នែកព័ត៌មានជាតិ លោកបានរៀនសូត្រយ៉ាងច្រើនអំពីដំណើរការក្នុងស្ថាប័នស្តង់ដាមួយក្នុងការផលិតអត្ថបទព័ត៌មានប្រចាំថ្ងៃ ក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ដំណើរនៃការផលិតអត្ថបទ របៀបសរសេរ និងទំនាក់ទំនងប្រភពផងដែរ។

លោក រ៉ូ គឹមឡុង បានបញ្ជាក់ថា ៖ «ខ្ញុំជឿជាក់ថា ការងារនោះបានបំភ្លឺឱ្យខ្ញុំស្គាល់ថា អ្វីទៅជាព័ត៌មានដែលមានស្តង់ដា និងក្រមវិជ្ជាជីវៈមានទម្រង់បែបណា។ ការធ្វើការងារនៅទីនោះគឺជាឱកាសមួយដែលពង្រឹងជំនាញរឹង និងជំនាញទន់ក្នុងផ្នែកសារព័ត៌មានបន្ថែមពីការសិក្សានៅក្នុងថ្នាក់រៀនកន្លងមក»។

ចំណែកអ្នកថតរូបវ័យក្មេង១រូបក្នុងប្រទេសកម្ពុជា លោកសុវណ្ណ ភីឡុង បានចូលប្រឡូកការងារជាអ្នកផ្គត់ផ្គង់រូបភាព (stringer) ក្នុងស្ថាប័នភ្នំពេញប៉ុស្ដិ៍នៅចុងឆ្នាំ២០០៨ ដែលលោកគិតថា ពេលនោះគឺជាពេលវេលាមួយដែលមានតម្លៃខ្លាំងមែនទែន ដោយសារអំឡុងពេលនោះ លោកគ្រាន់តែជាអ្នកទើបតែរៀនថតរូប ស្គាល់ពីការថតរូបទូទៅបន្តិចបន្តួច ប៉ុន្តែលោកមិនដែលមានបទពិសោធក្នុងការថតរូបផ្នែកសារព័ត៌មានទាល់តែសោះ។

លោក សុវណ្ណ ភីឡុង ដែលសព្វថ្ងៃជាអនុប្រធានសមាគមរូបថតភ្នំពេញ បានឱ្យដឹងថា លោកបានចូលប្រឡូកអាជីពជាអ្នកថតរូបផ្នែកសារព័ត៌មាន ជាមួយនឹងកាសែតភ្នំពេញប៉ុស្ដិ៍គឺជាបទពិសោធថ្មីដែលលោកធ្វើការផង និងរៀនសូត្រផង ដែលខុសពីអ្នកថតរូបផ្សេងៗទៀតដែលពួកគេមានបទពិសោធលើការងារនេះហើយ។

លោក អ៊ុត សូធឿត ទី៥ (ពីឆ្វេងមកស្តាំ)និងលោក សុវណ្ណ ភីឡុង ទី៦ (ពីឆ្វេងមកស្តាំ)។ រូបថត ភ្នំពេញប៉ុស្ដិ៍

លោក រ៉ូ គឹមឡុង អតីតអ្នកហាត់ការសារព័ត៌មាន នៅកាសែតភ្នំពេញប៉ុស្ដិ៍។ រូបថត សហការី

លោកបានថ្លែងថា៖ «សម្រាប់ខ្ញុំការចូលមកក្នុងស្ថាប័នសារព័ត៌មានភ្នំពេញប៉ុស្ដិ៍នេះ គឺទទួលបានបទពិសោធថ្មីផង និងធ្វើការងារផង។ អ៊ីចឹងវាបានធ្វើឱ្យខ្ញុំរៀនសូត្របានច្រើនពីស្ថាប័នមួយនេះ»។

ក្នុងរយៈពេល៣ឆ្នាំ ដែលលោក តីឡុង បានធ្វើការនៅកាសែតភ្នំពេញប៉ុស្ដិ៍ បានធ្វើឱ្យលោកអាចស្វែងយល់ និងទទួលបានបទពិសោធច្រើន ដែលមិននឹកស្មាន តាំងពីរបៀបធ្វើការ ការទំនាក់ទំនងជាមួយមិត្តរួមការងារ ជាពិសេសគឺបានរៀនសូត្រអភិវឌ្ឍខ្លួនឯងនៅក្នុងការប្រើប្រាស់ភាសា។

លោក សុវណ្ណ ភីឡុង បានថ្លែងថា ស្ថាប័នភ្នំពេញប៉ុស្ដិ៍បានបញ្ជូនលោកទៅធ្វើការជាមួយនឹងតារាហូលីវូដដ៏ល្បីគឺលោក Jacky Chan ឬឈិន ឡុង និងអ្នកល្បីល្បាញមួយចំនួនទៀត នៅក្នុងគម្រោងដែលមានការសហការជាមួយនឹងកាសែតភ្នំពេញប៉ុស្ដិ៍នៅក្នុងរាជធានីភ្នំពេញ។

អ្នកថតរូបដដែលនេះបានសង្កត់ធ្ងន់ថា៖«សម្រាប់ខ្ញុំ គឺខ្ញុំមានមោទនភាពដែលបានធ្វើការនៅកាសែតភ្នំពេញប៉ុស្ដិ៍ពីឆ្នាំ២០០៩ ដល់២០១១។ កាសែតភ្នំពេញប៉ុស្ដិ៍បានជួយខ្ញុំឱ្យមានគំនិតថ្មីៗច្រើន ដែលធ្វើឱ្យខ្ញុំមានឱកាសដើម្បីបានចូលរួមនូវរគ្គបណ្តុះបណ្តាលសិក្ខាសាលាជាមួយនឹងអ្នកថតរូបបរទេស និងអ្នកផ្សេងៗមួយចំនួនទៀត»។

នាយកប្រព័ន្ធផ្សព្វផ្សាយនៃមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) លោក អ៊ុត សូធឿត បានប្រាប់ភ្នំពេញប៉ុស្ដិ៍ថា សម្រាប់ស្ថាប័នសារព័ត៌មានដែលលោកបានចូលប្រឡូកការងារមុនគេ គឺស្ថាប័នកាសែតភ្នំពេញប៉ុស្ដិ៍ ដោយលោកបានចាប់ផ្តើមត្រឹមជាអ្នកហាត់ការប៉ុណ្ណោះ និងមានរយៈពេល២ខែក្នុងពេលវិស្សមកាលបន្ទាប់ពីបញ្ចប់ការសិក្សាឆ្នាំទី ២នៅដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍(DMC)ក្នុងឆ្នាំ ២០០៩-២០១០។

លោកបានប្រាប់ថា៖ «ក្នុងអំឡុងពេលនោះ ខ្ញុំបានរៀនសូត្របានច្រើនដោយទទួលបានបទពិសោធផ្ទាល់នៅក្នុងការសរសេរព័ត៌មាន ចុះយកព័ត៌មាន ជួបប្រភពព័ត៌មានផ្ទាល់ទាំងមន្ត្រីតូច-ធំ និងប្រជាពលរដ្ឋទូទៅផងដែរ។ ខ្ញុំក៏បានបន្តធ្វើការនៅកាសែតនេះទៀតក្នុងនាមជាអ្នកហាត់ការពេញម៉ោង (fellowship) រយៈពេលជិត១ឆ្នាំ ដែលធ្វើឱ្យខ្ញុំអាចបន្តជីវិតក្នុងវិស័យសារព័ត៌មានបន្ថែមទៀត»។ លោកបានបញ្ជាក់ថា ទាំងនេះគឺជាមូលដ្ឋានមួយដែលធ្វើឱ្យលោកបន្តការងារផ្នែកវិស័យសារព័ត៌មានជាបន្តបន្ទាប់រហូតមកដល់ពេលបច្ចុប្បន្ននេះ។

រដ្ឋលេខាធិការ និងជាមន្ត្រីនាំពាក្យក្រសួងបរិស្ថានលោក នេត្រ ភក្ត្រា បានចូលបម្រើការងារនៅកាសែតភ្នំពេញប៉ុស្ដិ៍ ពីខែវិច្ឆិកា ឆ្នាំ២០០៨ រហូតដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ ២០១១ ក្នុងហ៊ាន:ជាអនុប្រធានក្រុមអ្នកយកព័ត៌មាន និងបន្ទាប់មកជានាយកគ្រប់គ្រងការីនិពន្ធកាសែតភ្នំពេញប៉ុស្ដិ៍ភាសាខ្មែរ មុននឹងលោកចាប់អាជីពថ្មីជាមន្ត្រីនាំពាក្យនៅតុលាការខ្មែរក្រហមនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ ២០១១។

លោក នេត្រ ភក្ត្រា បានប្រាប់ថា៖ «កាសែតភ្នំពេញប៉ុស្ដិ៍ ជាទីដែលបានធ្វើឱ្យខ្ញុំកាន់តែមានភាពរឹងមាំក្នុងអាជីពសារព័ត៌មាន ផ្តល់បទពិសោធការងារ និងមានឱកាសយកទ្រឹស្ដីសិក្សានៅសាលាផ្នែកសារព័ត៌មាន បទពិសោធពីកម្មសិក្សានៅប្រទេសបារាំងមកអនុវត្តទាំងជំនាញសរសេរ និងជំនាញគ្រប់គ្រងក្នុងវិស័យសារព័ត៌មាន»។

ជាអ្នកដែលបានរួមចំណែកដ៏ធំក្នុងការបង្កើតកូនដោយផ្ទាល់ដៃ១រូបគឺ «កាសែតភ្នំពេញប៉ុស្ដិ៍ភាសាខ្មែរ»ក្នុងឆ្នាំ២០០៩ លោក នេត្រ ភក្ត្រា បានលើកឡើងថា រយៈពេលដែលលោកបានបំពេញការងារ នៅកាសែតនេះ អ្វីដែលលោកមិនបានបំភ្លេចបានគឺកាសែតនេះ បានដើរតួនាទីយ៉ាងសំខាន់ជាសំឡេងកម្ពុជាអំឡុងពេលជម្លោះរវាងកម្ពុជា និងថៃនៅតំបន់ប្រាសាទព្រះវិហារ និងជាមធ្យោបាយផ្តល់ព័ត៌មានពិតអំពីកម្ពុជាទៅកាន់សាធារណជន។ លោកថា៖ «អ្វីដែលសប្បាយចិត្តពេលថ្នាក់ដឹកនាំ ពិសេសសម្តេចតេជោនាយករដ្ឋមន្ត្រីមានប្រសាសន៍ លើកពីឈ្មោះកាសែតភ្នំពេញប៉ុស្ដិ៍ក្នុងសុន្ទរកថា និងពេលខ្លះលើកបង្ហាញរូបភាពកាសែតជាសាធារណៈ ដូចជាព័ត៌មានទាក់ទងនឹងលោកតារួមរឹត មិត្តភក្តិរបស់ព្រះបរមរតនកោដ្ឋជាដើម»។

សារព័ត៌មានបានដើរតួនាទីយ៉ាងសំខាន់ចូលរួមគ្រប់គ្រងសភាពការណ៍ប្រទេសជាតិ ចូលរួមធ្វើឱ្យមានស្ថិរភាពជាតិ និងការយល់ដឹងរបស់ប្រជាពលរដ្ឋដោយផ្តល់ព័ត៌មានពិតរហ័ស និងទុកចិត្តដោយឈរលើមូលដ្ឋានប្រភពព័ត៌មានច្បាស់លាស់៕

លោក Eli Lillis អតីតអ្នកហាត់ការផ្នែកថតរូបនៅកាសែតភ្នំពេញប៉ុស្ដិ៍ រយៈពេល ៧ខែ គឺចាប់ពីចុងឆ្នាំ ២០១៦ ដល់ពាក់កណ្តាលឆ្នាំ២០១៧។

លោកបានប្រាប់ឱ្យដឹងថា កម្មសិក្សានៅកាសែតភ្នំពេញប៉ុស្ដិ៍គឺជាមុខតំណែងដំបូងរបស់លោក បន្ទាប់ពីលោកបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ ដែលចំណេះដឹងដែលលោកទទួលបានពីការងារនេះគឺទូលំទូលាយសម្រាប់លោក។

លោក Eli Lillis បញ្ជាក់ថា៖ «ការរៀនពីការពិតប្រចាំថ្ងៃរបស់អ្នកសារព័ត៌មាន ទាំងល្អ និងអាក្រក់ គឺជាមេរៀនដ៏ធំបំផុត។ អត្ថប្រយោជន៍ដ៏ធំបំផុតដែលខ្ញុំទទួលបានពីការងារនៅទីនោះ គឺខ្ញុំដឹងពីអ្វីដែលខ្ញុំចាប់អារម្មណ៍ ហើយធ្វើឱ្យការថតរូបខ្ញុំមានការរីកចម្រើនផងដែរ»។

លោក Eli Lillis ថា លោកនឹងនៅតែនឹករឭកនូវការដឹងគុណជារៀងរហូតសម្រាប់ពេលវេលារបស់លោកនៅកាសែតភ្នំពេញប៉ុស្ដិ៍នេះ ហើយលោកក៏សង្ឃឹមផងដែរថា កាសែតនេះនឹងនៅតែមានវត្តមានយូរអង្វែងតទៅមុខទៀត៕ ■

ផ្ទេរ និងទទួលប្រាក់

ភ្លាមៗទូទាំងពិភពលោក

WesternUnion WU MoneyGram. money transfer Thunes.

ACLEDA mobile
App Store Google Play AppGallery

អេស៊ីលីដា ACLEDA BANK

កម្ពុជាបានប្រែក្លាយវិស័យកសិកម្មពីការពឹងផ្អែកលើការនាំចូលទាំងស្រុងមកជាប្រទេសនាំចេញ

កសិករកំពុងលើកកសិផលរបស់ខ្លួន ដើម្បីលក់ឱ្យឈ្មួញនៅទឹកដីនៃខេត្តព្រះវិហារនាពេលកន្លងមក។ រូបថត វ៉ាស់ហ៊ីម

ហំ ផានិត

ភ្នំពេញ: កំណើននៃតម្លៃបន្ថែមសរុបរបស់វិស័យកសិកម្មបានកើនឡើងពី ១៥ ៩៣៨ពាន់លានរៀល ឬស្មើនឹងជាង ៣ ៩០៩លានដុល្លារនៅឆ្នាំ ២០១០ ដល់ ២២ ៧៨៦ពាន់លានរៀល ឬស្មើនឹង ៥ ៥៨៣លានដុល្លារនៅឆ្នាំ២០១៩ មុនពេលមានវិបត្តិកូវីដ ១៩ ដោយបានកើនក្នុងអត្រាប្រមាណ ៤% ក្នុង១ឆ្នាំនៅក្នុងរយៈពេល១០ឆ្នាំមកនេះ។

របាយការណ៍ស្តីពីការអភិវឌ្ឍវិស័យកសិកម្មកម្ពុជានៅក្នុងរយៈពេល១០ឆ្នាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបង្ហាញថា កំណើននៃវិស័យកសិកម្មមានប្រមាណ១,៧% នៅឆ្នាំ ២០១៧ និង ១,១% នៅឆ្នាំ២០១៨។ ចាប់ពីដើមឆ្នាំ២០២០ ដោយសារវិបត្តិនៃការឆ្លងរាលដាលជំងឺកូវីដ១៩ បានធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច រីឯកំណើននៃវិស័យកសិកម្មស្ថិតក្នុងរង្វង់ ០,៦% តែប៉ុណ្ណោះ ហើយកំណើននេះត្រូវបានប៉ាន់ស្មានថានឹងកើនប្រហែល ១,១% នៅឆ្នាំ ២០២១។ ចំពោះការចូលរួមចំណែកនៃអនុវិស័យក្នុងវិស័យនេះបង្ហាញឱ្យឃើញថា ផលិតកម្មដំណាំបានរួមចំណែកធំជាងគេ គឺប្រមាណពី៥៧% ទៅ៥៩% នៃផលិតផលកសិកម្មសរុប ខណៈដែលផលិតផលជលផលមានប្រមាណពី២២% ទៅ២៤% ផលិតផលសត្វមានក្នុងរង្វង់ជាង ១១% និងព្រៃឈើមានក្នុងចន្លោះពី៦,៧% ទៅ ៧% ប៉ុណ្ណោះ។

ចំពោះអនុវិស័យដំណាំ ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ ផលិតផលស្រូវបានកើនឡើងពី ៨,២លានតោននៅឆ្នាំ២០១០ ដល់១០,៨លានតោននៅឆ្នាំ២០១៩ (មានកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ ៣,១%) ហើយនៅឆ្នាំ២០២១ សម្រេចបាន ១២,២១លានតោន។ នៅក្នុងនោះ អតិរេកស្រូវបានកើនពី ៣,៩លានតោននៅឆ្នាំ២០១០ ដល់ ៥,៧៥ លានតោននៅឆ្នាំ២០១៩ និង៦,៩ លានតោននៅឆ្នាំ២០២១នេះ។ ដោយឡែកផលិតផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មបានកើនពី ៦,១៤លានតោននៅឆ្នាំ២០១០ និងនៅឆ្នាំ២០២១ សម្រេចបានជាង១៩ លានតោន។ចំពោះផលិតផលកៅស៊ូ សម្រេចបានជាង ៤២ពាន់តោននៅឆ្នាំ២០១០ និងកើនដល់ ២៨៧ពាន់តោននៅឆ្នាំ២០១៩ និងនៅឆ្នាំ ២០២១ សម្រេចបានជាង ៣៦៨ ពាន់តោន។ ការនាំចេញផលិតផលកៅស៊ូមានការកើនឡើងពី ៤២ពាន់តោន នៅឆ្នាំ២០១០ ដល់ ៣៦៦ ពាន់តោន នៅឆ្នាំ២០២១។

សម្រាប់អនុវិស័យផលិតកម្មសត្វ (លក្ខណៈគ្រួសារ និងលក្ខណៈពាណិជ្ជកម្ម) មានកំណើន៥,៥៣% ជាមធ្យមប្រចាំឆ្នាំ។នៅឆ្នាំ២០១០ ការចិញ្ចឹមសត្វមានចំនួន ២៧លានក្បាល និងកើនដល់ជាង៤៥លានក្បាលនៅឆ្នាំ ២០១៩ (បើគិតជាតម្លៃគឺកើនពី១ ៤៥ ៨លានដុល្លារអាមេរិក ដល់ ១ ៨២៧ លានដុល្លារអាមេរិក) ហើយនៅឆ្នាំ ២០២១ ចិញ្ចឹមបានជាង ៥៩លាន ក្បាល។ ផ្នែកជលផលវិញ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ បរិមាណផលនេសាទសរុប (ទឹកសាប សមុទ្រ និងវារីរបឹកម្ម) បានកើនឡើងប្រមាណ ៥,៧% ជាមធ្យមក្នុង១ឆ្នាំៗគឺ ៥៥០ ពាន់តោននៅឆ្នាំ២០១០ ដល់ ៨៥៦ ពាន់តោននៅឆ្នាំ២០២១។ ផលនេសាទទឹកសាប កើនពី៤០៥ពាន់តោននៅឆ្នាំ២០១០ ដល់៤៧៩ពាន់តោននៅឆ្នាំ២០១៩ (ប្រមាណ ១,៩% ជាមធ្យមប្រចាំឆ្នាំ) និង ៣៨៣ពាន់តោននៅឆ្នាំ២០២១។បរិមាណផលនេសាទសមុទ្របានកើនឡើងដូចគ្នាពី ៨៥ពាន់តោននៅឆ្នាំ២០១០ ដល់ជាង ១២២ពាន់តោននៅឆ្នាំ២០១៩ (ប្រមាណ៤,១%ជាមធ្យមប្រចាំឆ្នាំ) និងនៅឆ្នាំ២០២១ មានចំនួន ១២៥ ពាន់តោន។ ចំណែកផលវារីរបឹកម្ម បានកើនឡើងពី ៦០ពាន់តោន ដល់ជាង ៣០៧ពាន់តោន ក្នុងចន្លោះឆ្នាំ ២០១០ និងឆ្នាំ២០១៩ (ប្រមាណ ១៩,៩%ជាមធ្យមប្រចាំឆ្នាំ) និងនៅឆ្នាំ ២០២១នេះ សម្រេចបាន ៣៤៨ពាន់តោន។

ចំពោះវិស័យព្រៃឈើវិញក្នុងរយៈពេល១០ឆ្នាំកន្លងទៅនេះ ការដាំឈើឡើងវិញ ទាំងរដ្ឋ និងវិស័យឯកជន សម្រេចបានសរុបចំនួន ៤០៨ពាន់ហិកតា និងការបង្កើតសហគមន៍ព្រៃឈើ គិតត្រឹមឆ្នាំ២០១៩ មានសរុបចំនួន ៦៣៦សហគមន៍ និងកើនដល់ ៦៤៣ សហគមន៍ត្រឹមឆ្នាំ២០២១នេះ។

ទន្ទឹមនឹងភាពរីកចម្រើនដូចដែលមាននៅក្នុងរបាយការណ៍នេះ វិស័យកសិកម្មក៏នៅជួបប្រទះបញ្ហាប្រឈមមួយចំនួន ដែលទាក់ទងផ្នែកវារីរបឹកម្ម ផ្នែកដំណាំ ទីផ្សារ ដែលធ្វើឱ្យការនាំចេញផលិតកម្មរបស់កម្ពុជានៅមានកម្រិត។ នេះបើតាមការបញ្ជាក់បន្ថែមពីលោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម។

លោក សាខុន បានបន្ថែមថា ផលិតភាពកសិកម្មនៅកម្ពុជាមានកម្រិតទាបបើធៀបជាមួយប្រទេសដទៃទៀតក្នុងតំបន់ ដោយហេតុថា ការធ្វើទំនើបកម្មប្រព័ន្ធផលិតកម្មទើបតែចាប់ផ្តើម និងក្នុងល្បឿនយឺត, យន្តកម្មកសិកម្ម និងការប្រើប្រាស់ជាតុចូលកសិកម្មសមស្របដែលតម្រូវឱ្យមានការលើកកម្ពស់ការយល់ដឹងបន្ថែមទៀត និងសមត្ថភាពក្នុងការផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទំនើបនៅមិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ។

លោកបានបញ្ជាក់ថា៖«កម្ពុជាពិបាកក្នុងការប្រកួតប្រជែងតម្លៃនៅលើទីផ្សារ ដោយសារតែប្រទេសជិតខាងកម្ពុជាចំណាយថ្លៃដើមលើផលិតផលកសិកម្មនេះតិចជាងយើង ដូចនេះគេអាចលក់បានក្នុងតម្លៃទាបជាងយើង»។

លោកបានបន្តថា ការនាំចេញទៅកាន់ទីផ្សារអន្តរជាតិ ជាពិសេសតំបន់អឺរ៉ុប ក្រៅពីស្រូវអង្ករកម្ពុជាអាចនាំទៅបានត្រឹម១៥០តោនប៉ុណ្ណោះក្នុង១ឆ្នាំ ដោយសារតែជួបការលំបាកច្រើនរឿងបញ្ហាដឹកជញ្ជូនប៉ុន្តែបើនាំមកកាន់ប្រទេសជិតខាងវិញ ពិបាកក្នុងការប្រកួតប្រជែងជាមួយផលិតផលក្នុងស្រុករបស់គេ។ ម៉្យាងវិញទៀត បើសិនជានាំចេញទៅចិន ជប៉ុន កូរ៉េ ក៏មានការលំបាកច្រើនដែរ ដោយសារតែនៅមានរបាំងភូតគាមអនាម័យ ដោយត្រូវចំណាយច្រើន និងចំណេញតិចជាពិសេសផលិតផលផ្លែឈើដែលមានសក្តានុពលដូច ស្វាយ និងចេកជាដើម កំពុងជួបបញ្ហាច្រើនក្នុងការនាំចេញទៅកាន់ប្រទេសចិន។

ទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យានៅក្នុងវិស័យកសិកម្មវិញ ត្រូវបានលោករដ្ឋមន្ត្រីគូសបញ្ជាក់ថា បានជួយកាត់បន្ថយការប្រើប្រាស់កម្លាំងពលកម្មច្រើន ទទួលបានផល និងគុណភាពល្អប្រសើរជាងមុន ខណៈកំណើននៃការប្រើប្រាស់បច្ចេកវិទ្យាក្នុងវិស័យកសិកម្មមានកាន់តែច្រើនពី១ឆ្នាំទៅ១ឆ្នាំ។

អគ្គលេខាធិការសហព័ន្ធស្រូវអង្ករកម្ពុជា លោក លន់ យ៉ែង បានមានប្រសាសន៍ថា ក្នុងរយៈពេល ១០ឆ្នាំចុងក្រោយ តាមរយៈការដាក់ចេញនូវគោលនយោបាយផលិតកម្មស្រូវ និងជំរុញការនាំចេញរបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០១០។ លោកថា កម្ពុជាពីប្រទេសដែលសម្រាប់តែធ្វើផលិតកម្មស្រូវសម្រាប់សន្តិសុខស្បៀងក្នុងស្រុក រហូតដល់ការនាំចេញស្រូវបានជាង ៣,៥លានតោនស្រូវនៅក្នុងឆ្នាំ២០២១ ហើយបានចាប់ផ្តើមនាំចេញអង្ករត្រឹមចំនួន ប្រមាណជាង ១ ម៉ឺនតោន នៅឆ្នាំ ២០០៩ និងកើនដល់ជាង ៦១ម៉ឺនតោននៅឆ្នាំ២០២១។

អ្នកជំនាញផ្នែកកសិកម្មនៅកម្ពុជា លោក យ៉ង សាំងកុមារ បានមើលឃើញថា ការវិវឌ្ឍនៃវិស័យកសិកម្មកម្ពុជាមានតិចតួចប៉ុណ្ណោះ ខណៈដែលការកង្វះទីផ្សារ និងទុន នៅតែជាកង្វល់ និងបញ្ហាសម្រាប់កសិករមិនទាន់មានការដោះស្រាយឱ្យបានល្អប្រសើរនៅឡើយ។

លោកបានថ្លែងបញ្ជាក់ថា៖«យើងសង្កេតឃើញថា មិនមានការវិវឌ្ឍជាវិជ្ជមានច្រើនទេ សម្រាប់វិស័យកសិកម្មកម្ពុជា ដោយសារតែបញ្ហាបំណុលរបស់កសិករនៅតែមានច្រើន ការប្រែក្លាយដីកសិកម្មទៅជាដីឡូត៍ និងការស្រាវជ្រាវលើបច្ចេកទេសកសិកម្មទាំងនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាននៅមានកម្រិតនៅឡើយ។ ទោះជាយ៉ាងណាយើងក៏យើញមានការវិវឌ្ឍល្អប្រសើរខ្លះដែរ គឺផ្ទៃដីដាំដំឡូងមី និងស្វាយចន្ទីមានការកើនឡើងគួរសម ប៉ុន្តែនៅតែមានបញ្ហាទីផ្សារដដែល»។

ដើម្បីជំរុញកំណើនផលិតភាពកសិកម្មកម្ពុជា រាជរដ្ឋាភិបាល តាមរយៈក្រសួងកសិកម្មបានរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្មកម្ពុជាឆ្នាំ២០២២-២០៣០ ដើម្បីប្រែក្លាយ កសិកម្មកម្ពុជា ជាកសិកម្មទំនើប មានលក្ខណៈប្រកួតប្រជែងបរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាព ដែលនឹងធ្វើឱ្យកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា៕ ■

លោក វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ រូបថត ជីវ័ន

បេសកកម្មផ្សព្វផ្សាយតំបន់ទេសចរណ៍នៅតែបន្តក្នុងបរិបទវិបត្តិកូវីដសកល

ហុង រស្មី

ភ្នំពេញ ៖ អស់រយៈពេលជាច្រើនឆ្នាំមកហើយ សារព័ត៌មាន ភ្នំពេញ ប៉ុស្ដ៍ បានចុះរុករក និងផ្សព្វផ្សាយពីតំបន់ដ៏ស្រស់ស្អាតដ៏មានសក្ដានុពលនៅកម្ពុជា ដើម្បីលើកកម្ពស់វិស័យទេសចរណ៍ និងពលរដ្ឋសហគមន៍។

ទោះជាឆ្លងកាត់វិបត្តិជំងឺកូវីដ១៩ជាសកលក្ដី ក៏បេសកកម្មនេះនៅតែបន្តដោយសម្របតាមរបត់សកល និងវិធានការសុវត្ថិភាព ដូចជាការបង្វែទិសដៅទៅរកបច្ចេកវិទ្យាទេសចរណ៍ពិភពនិម្មិត អំឡុងពេលបិទខ្ទប់ការណែនាំតំបន់ទេសចរណ៍បែបផ្សងព្រេង ដោយមានការចូលរួមពីស្ត្រី និងការបំបែកឯតទគ្គកម្មស្ដារអេកូទេសចរណ៍នៅកម្ពុជា។

ពិភពនិម្មិតក្នុងវិស័យទេសចរណ៍

អំឡុងពេលផ្ទុះការឆ្លងក្នុងសហគមន៍នៅកម្ពុជា ប្រជាជនមិនត្រូវបានលើកទឹកចិត្តឱ្យធ្វើដំណើរ ចៀសវាងការជួបជុំមនុស្សច្រើន ខណៈអាជីវកម្មភ្ញាន ជាច្រើនត្រូវបានបិទទ្វារ។

យ៉ាងណាមិញ ក្នុងកាលៈទេសៈនេះ បច្ចេកវិទ្យា VR អាចជួយ និងនាំយកទិដ្ឋភាពទាំងនោះមកដល់ក្នុងបន្ទប់សម្រាប់អ្នកត្រូវសំងំក្នុងផ្ទះរយៈពេលច្រើនថ្ងៃ សប្ដាហ៍ ឬរហូតដល់ខែ។

លោក អៀ សារ៉ាបុត្រ ជាស្ថាបនិក Virtual Reality Cambodia និងជានាយកគ្រប់គ្រង Hiverlab Cambodia បានឱ្យដឹងថា៖«យើងអាចទៅលេងអង្គរវត្ត យើងទៅសមុទ្រ ទៅកោះ ទៅស្រុកអីផ្សេងទៀត ដូចជា ក្រុងប៉ារីស អូស្ត្រាលី និងគ្រប់កន្លែង រួមទាំងទិដ្ឋភាពបាតសមុទ្រនៅក្នុងកម្រិតរូប ៣៦០ដឺក្រេ»។

បទពិសោធបច្ចេកវិទ្យាទំនើបក្នុងវិស័យទេសចរណ៍នេះ ក៏ត្រូវបានប្រើប្រាស់ដោយសារមន្ទីរអន្តរជាតិនានា ដោយរំលេចពិព័រណ៌ដ៏រស់រវើក ទាក់ទាញអ្នកទស្សនាវិលទៅកាន់ពេលវេលាណាមួយ និងកន្លែងណាមួយស្ដែងៗនឹងភ្នែក។

អង្គរវត្តរស់រវើក មានន័យថា ភ្ញៀវអាចធ្វើដំណើរទៅកាន់អតីតកាល ដើម្បីមើលពីការកសាងប្រាង្គប្រាសាទក្នុងរជ្ជកាលអាណាចក្រខ្មែរដ៏រុងរឿងផ្ទាល់នឹងភ្នែក ដោយគ្រាន់តែឈានជើងចូលក្នុងសាលបន្ទប់ធំមួយនោះ រូបភាពពីការកសាងប្រាង្គប្រាសាទបានផុសឡើងនៅគ្រប់ជ្រុងនៃជញ្ជាំងទាំង៨ទិស ពេញ៣៦០ដឺក្រេ។

លោក សូរស្មី កេ ប៊ីន ជាអគ្គនាយកក្រុមហ៊ុន Confluences ដែលរួមចំណែកក្នុងការបង្កើតសារមន្ទីរអង្គរវត្តរស់រវើក បាននិយាយថា៖«ក្នុងការផ្ដល់បទពិសោធសម្រាប់ទាំងភ្ញៀវជាតិ និងអន្តរជាតិ សារមន្ទីរអង្គរវត្តរស់រវើក នឹងប្រើបច្ចេកវិទ្យាទំនើប ដែលអនុញ្ញាតឱ្យអ្នកទស្សនាបានឃើញនូវប្រាង្គប្រាសាទត្រូវបានកសាងឡើងវិញតាមរូបភាព 3D»។

នៅពេលរដ្ឋាភិបាលចាប់ផ្ដើមដកការរឹតបន្តឹងសន្សឹមៗ កញ្ញា ថូ ភារម្យ បានសម្រេចចិត្តសាកល្បងដំណើរបែបផ្សងព្រេងលើកដំបូង កាលពីខែកក្កដា ឆ្នាំ២០២១ ឡើងភ្នំខ្ពងផ្សារ។

ក្រោយដំណើរថ្មើរជើង៥ម៉ោងតបស្នងដោយទេសភាពវាលស្មៅលើភ្នំរលកលេញបំពេញដោយពពកអ័ព្ទសក្បុសកញ្ញានិយាយថា៖«ខ្ញុំចង់សាកឬឱ្យជីវិត»។

ប៉ុន្មានឆ្នាំចុងក្រោយនេះ ស្ត្រីកាន់តែច្រើនហ៊ានផ្សងព្រេងធ្វើដំណើរកម្សាន្តផ្សារភ្ជាប់ខ្លួនជិតស្និទ្ធនឹងសហគមន៍ទេសចរណ៍ធម្មជាតិ។

ដូចជាកញ្ញា ផេង ស្រីស សកម្មជនបរិស្ថាន ១រូប ដែលបានធ្វើដំណើរជុំវិញប្រទេសកម្ពុជា ជាពិសេសតំបន់ព្រៃភ្នំ នារយៈពេល៥ឆ្នាំចុងក្រោយនេះ។

ក្រៅពីភ្នំខ្ពស់បំផុតទាំង៣ នៅកម្ពុជា ដូចជា ភ្នំឱរ៉ាល់ កម្ពស់ ១ ៨១៣ម៉ែត្រ ខេត្តកំពង់ស្ពឺ ភ្នំសំកុស កម្ពស់ ១ ៧១៧ ម៉ែត្រ ខេត្តពោធិ៍សាត់ និងភ្នំទំព័រ កម្ពស់ ១ ២៥០ម៉ែត្រក្នុងខេត្តពោធិ៍សាត់ យុវតីខ្មែររូបនេះបានធ្វើដំណើរចូលព្រៃភ្នំជាច្រើនកន្លែង។ កញ្ញា ស្រីស បានចំណាយពេល ១០ថ្ងៃ ធ្វើដំណើរទៅកាន់ឆាយ១០០ ឬជ្រោះមរណៈ ស្ថិតនៅកណ្ដាលព្រៃជ្រោនៃតំបន់ជួរភ្នំក្រវាញ ព្រំប្រទល់ខេត្តកោះកុង និងពោធិ៍សាត់ ជ្រលងភ្នំខ្ពស់ៗ និងស្ទឹងធំៗ។

កញ្ញាវ័យ២៦ឆ្នាំនេះបានប្រាប់ថា៖«កម្លាំងយើងជាមនុស្សស្រីប្រហែលជាមិនខ្លាំងដូចបុរសទេ ប៉ុន្តែកម្លាំងចេញពីចិត្ត និងក្ដីស្រឡាញ់ធម្មជាតិអាចធ្វើឱ្យយើងជម្នះឧបសគ្គបាន»។

ទំនោរទេសចរណ៍ធម្មជាតិ

បន្ថែមពីការផ្សព្វផ្សាយពីទំនោរកម្សាន្តបែបផ្សងព្រេង ភ្នំពេញ ប៉ុស្ដ៍ ក៏ព្យាយាមរំលេចសក្ដានុពលសកម្មភាពកម្សាន្តប្រកបដោយសុវត្ថិភាព និងបណ្ដុះគ្រាប់ពូជអ្នកស្នេហាបរិស្ថាន។

កុមារី វ័យ ៨ឆ្នាំ ភិរម្យ រស្មីភាណុ ទើបបញ្ចប់ដំណើរទៅកាន់វាលខ្នងផ្សារ និងបងប្រុស វីលៀមស៍ អាយុ ៨ឆ្នាំ ក៏បានទទួលជោគជ័យក្នុងការឡើងភ្នំខ្ពស់បំផុតនៅកម្ពុជាផងដែរ។

កុមារទាំង២ជាកូនរបស់លោក ជួន ភិរម្យ បុគ្គលល្បីខាងពូកែលុកលុយព្រៃភ្នំ ស្វែងរកទីឋានធម្មជាតិស្រស់ត្រកាល ដោយមែងចែករំលែកចំណេះដឹងស្ដីពីបទពិសោធដើរផ្សងព្រេង និងសម្អាតបរិស្ថាន។

លោកប្រាប់ថា៖ «ដំណើរកម្សាន្តបែបផ្សងព្រេងនេះផ្ដល់អត្ថប្រយោជន៍ដល់ក្មេងៗក្នុងការបង្កើនទំនុកចិត្តលើខ្លួនឯង និងជាឱកាសឱ្យគាត់ផ្សារភ្ជាប់ជាមួយធម្មជាតិ ហ្វឹកហ្វឺនរាងកាយបានយ៉ាងល្អ និងជាការអប់រំមួយបែបនៅពេលគាត់ឡើងភ្នំ គាត់អាចឮសំឡេង ក្លិន និងឃើញនូវអ្វីប្លែកៗ»។ លោកបន្ដថា៖ «អំឡុងពេលដើរនោះ យើងអាចពន្យល់គាត់ពីសារៈសំខាន់នៃបរិស្ថាន និងអាចបង្រៀនគាត់អំពីចំណេះដឹងមូលដ្ឋាននៃការរស់នៅក្នុងព្រៃ ព្រមទាំងអនុវត្តគោលការណ៍«ដើរមិនទុកដាន» ផងដែរ»។

កំណត់ត្រាស្ដារអេកូទេសចរណ៍

ក្នុងគោលបំណងស្ដារអេកូទេសចរណ៍ឱ្យរស់ឡើងវិញ ក្រោយញាំញីដោយកូវីដ អង្គការក្រៅរដ្ឋាភិបាលវ័យសាមប្លាយជាជនជាតិអាមេរិក លោក Jacob Sims និងអូស្ត្រាលី Julien Brewster បានបំបែកកំណត់ត្រាឡើងភ្នំឱរ៉ាល់ ក្នុងចិរវេលា ២ ម៉ោង ២៦នាទី និង ៣៦វិនាទី នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០២២ ហើយលោកបានលើកទឹកចិត្តឱ្យអត្តពលិកខ្មែរចូលរួមបំបែកកំណត់ត្រារបស់លោក។

ក្រោយពីបានឃើញព័ត៌មាននេះលើកាសែត ភ្នំពេញ ប៉ុស្ដ៍ ពីលោក គីម សារឿន ហៅ គីម កុក អាយុ ៥៣ឆ្នាំរូបនេះ បានឡើងដល់កំពូលភ្នំឱរ៉ាល់ដោយប្រើប្រាស់ចិរវេលាចំនួន ២ម៉ោង ២៦នាទី និង ៨វិនាទី កាលពីថ្ងៃសៅរ៍ទី៤ មិថុនា២០២២។

លោកបញ្ជាក់ថា៖ «នេះមិនមែនជាការអំពាវនាវឱ្យមានការប្រកួតប្រជែងគ្នាឡើយ ប៉ុន្តែជាការលើកទឹកចិត្តឱ្យមកបំបែកកំណត់ត្រារបស់ខ្លួនឯង និងលើកកម្ពស់វិស័យទេសចរណ៍ បង្កើនជីវភាពសហគមន៍ឱ្យកាន់តែរីកចម្រើន»៕ ■

អបអរសាទរ ខួបលើកទី៣០នៃកាសែតភ្នំពេញប៉ុស្ដ៍

CONGRATULATIONS PHNOM PENH POST ON YOUR 30TH ANNIVERSARY

30 YEARS The Phnom Penh Post



Brainchild of Cambodia's most celebrated chef cum entrepreneur **Luu Meng**, Kanji now serves **"Omakase"** set menus, carefully prepared by the Chefs using the finest and freshest ingredients available.

Kanji's many private dining rooms offer privacy; be it for a private event or celebration.

Make your reservation now at Kanji for a unique dining experience!

KAN JI カンジ JAPANESE RESTAURANT®

Hotline: 016 31 28 28 | Restaurant Manager: 016 20 68 88

@ Almond Hotel Sothearos, No 128F, Sothearos Boulevard, Tonle Bassac, Phnom Penh, Cambodia.

កម្ពុជា បានឱកាសធ្វើម្ចាស់ផ្ទះស៊ីហ្គេម ជាប្រវត្តិសាស្ត្រលើកដំបូង នៅឆ្នាំ២០២៣ បន្ទាប់ពីបានឆ្លងកាត់សង្គ្រាមស៊ីវិលជាបន្តបន្ទាប់

ឈន ណន

ភ្នំពេញ: ជាប្រទេសមួយដែលបានទទួលរងនូវការដាក់អាណានិគមពីបរទេស រួចកើតមានសង្គ្រាមរ៉ាំរ៉ៃ ក្នុងស្រុក ជាបន្តបន្ទាប់គ្នា អស់ជាច្រើនសម័យកាលនោះ កម្ពុជាបានខំប្រឹងរើបម្រះពីរបបសម័យកាលដ៏ជូរចត់ និងខ្មៅងងឹតទាំងនោះ រហូតអាចវិវឌ្ឍខ្លួនក្លាយជារដ្ឋមួយ ដែលទទួលបានសេរីភាពពេញលេញ និងមានសុខសន្តិភាព ដូចបច្ចុប្បន្ន។

ជាមួយគ្នានេះ វិស័យកីឡា ក៏ត្រូវបានយកចិត្តទុកដាក់ ពីរាជរដ្ឋាភិបាល ដើម្បីបង្កើតបានជាសហព័ន្ធកីឡាជាតិជាបន្តបន្ទាប់ ដើម្បីធ្វើការបណ្តុះ-បណ្តាលនូវធនធានកីឡា ទាំងក្រុម-អត្តពលិក និងមន្ត្រីបច្ចេកទេស ហើយក្នុងរយៈពេលជិត៤០ឆ្នាំចុងក្រោយមកនេះ កម្ពុជា បានបញ្ជូនប្រតិភូកីឡាចេញទៅប្រកួតប្រជែង នៅលើឆាក-អន្តរជាតិ ជាបន្តបន្ទាប់ និងដណ្តើមបានមេដាយជូនជាតិ ជាហូរហែ ជា-ពិសេសនៅក្នុងការប្រកួតស៊ីហ្គេម ដែលជាព្រឹត្តិការណ៍ដ៏ធំប្រចាំនៅតំបន់អាស៊ាន។

យ៉ាងណាក៏ដោយ ចាប់តាំងពីការ-ប្រកួតស៊ីហ្គេម ត្រូវបានបង្កើតឱ្យមានការប្រកួតជាលើកដំបូង នៅទីក្រុងបាងកក ប្រទេសថៃ ឆ្នាំ១៩៥៩ រហូតមកដល់ពេលនេះ កម្ពុជា មិនធ្លាប់បានធ្វើជាម្ចាស់ផ្ទះស៊ីហ្គេមនៅឡើយទេ ខណៈ:ថៃ និងម៉ាឡេស៊ី ធ្លាប់ធ្វើម្ចាស់-ផ្ទះ៦ដងដូចគ្នា ហើយឥណ្ឌូនេស៊ី សិង្ហបុរី និងហ្វីលីពីន បាន៤ដងដូចគ្នា រីង មីយ៉ាន់ម៉ា បាន៣ដង វៀតណាម បាន២ដង ហើយប្រ៊ុយណេ និងឡាវ បានធ្វើម្ចាស់ផ្ទះ១ដងដូចគ្នា តែទីម័រ-ខាងកើត នៅមិនទាន់ធ្លាប់បានធ្វើដូចកម្ពុជាដែរ។

តែទោះបីជាយ៉ាងណា ដោយមើលឃើញពីភាពរីកចម្រើន និងសក្តានុពលនៃវិស័យកីឡា នៅកម្ពុជា ដែលអាចដណ្តើមបានមេដាយគ្រប់កម្រិត ទាំងការប្រកួតជើងឯកពិភពលោក អាស៊ី និងអាស៊ាន ជាពិសេសការបំបែកកំណត់ត្រានៃការឈ្នះមេដាយមាសកីឡាអាស៊ី ជាបន្តបន្ទាប់គ្នារបស់អត្តពលិកកម្ពុជា និងការកើនឡើងនៃការ-ប្រមាញ់បានមេដាយមាស ក្នុងព្រឹត្តិ-ការណ៍ស៊ីហ្គេម ស្របពេលកម្ពុជាមានសុខសន្តិភាពផងនោះបានជំរុញឱ្យប្រមុខដឹកនាំប្រទេស លោកនាយក-រដ្ឋមន្ត្រី ហ៊ុន សែន សម្រេច និងអនុញ្ញាតឱ្យកម្ពុជា ទទួលសិទ្ធិធ្វើជាម្ចាស់ផ្ទះស៊ីហ្គេម ជាប្រវត្តិសាស្ត្រលើកដំបូង នៅឆ្នាំ២០២៣។

យ៉ាងណាក៏ដោយ ចំពោះការទទួលធ្វើម្ចាស់ផ្ទះស៊ីហ្គេមនេះ លោកនាយក-រដ្ឋមន្ត្រី ហ៊ុន សែន បានប្រាប់ទៅក្រុមមន្ត្រីជំនាញ និងអ្នកពាក់ព័ន្ធទាំងអស់កន្លងមកថា៖ «យើងត្រូវចងចាំឱ្យច្បាស់ថា យើងមានតួនាទីជាម្ចាស់ផ្ទះ ដូច្នេះយើងត្រូវធ្វើជាម្ចាស់ផ្ទះ ដែលមានការ-ទទួលខុសត្រូវ ហើយការប្រកួតត្រូវប្រព្រឹត្តទៅឱ្យរលូនពីដើមដល់ចប់ មិនធ្វើឱ្យកីឡាករ កីឡាការិនី និងអ្នកដឹកនាំនៃប្រទេសនានាដែលចូលរួមប្រកួតបាក់ទឹកចិត្ត ហើយធ្វើឱ្យខូចនូវមុខ-មាត់ប្រទេសយើងនោះទេ»។

លោក ទៀ បាញ់ បានបង្ហាញទង់ស៊ីហ្គេម បន្ទាប់ពីលោក និងប្រតិភូកីឡាកម្ពុជា បាននាំយកមកដល់ប្រទេសកម្ពុជា។ រូប ហេង ជីវ័ន

ប្រមុខដឹកនាំប្រទេសកម្ពុជារូបនេះ បានបន្ថែមថា៖ «ការដណ្តើមមេដាយជារឿងទី២ទេ ប៉ុន្តែរឿងធានាវ៉ាប់រងក្នុងហាន:ជាសមាជិកអាស៊ាន ដែលមានការទទួលខុសត្រូវ គឺត្រូវធ្វើការងារនេះឱ្យច្បាស់ ដោយមិនត្រូវធ្វើឱ្យអត្តពលិកមកពីប្រទេសនានា បាក់ទឹកចិត្ត ហើយត្រឡប់ទៅវិញ និយាយដើមពីកម្ពុជាថា ទទួលមិនបានល្អ ដេកមិនបានគ្រប់គ្រាន់ក្តៅនោះទេ ព្រោះពេលបើក យើងបើកចំពេលក្តៅទៅទៀត ដោយយើងកំណត់យកថ្ងៃសុក្រ ទី៥ ខែឧសភា ឆ្នាំ២០២៣»។

> ***ពេលនេះ ជាឱកាសដ៏វិសេសវិសាលមួយដែលខ្ញុំសូមរំឭកឡើងវិញថា កម្ពុជា បានរង់ចាំរយៈពេល៦៤ឆ្នាំ ទើបអាចមានលទ្ធភាពទទួលធ្វើជាម្ចាស់ផ្ទះស៊ីហ្គេមដ៏ធំនេះ ក្រោមគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់និងប៊ិនប្រសប់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន...***

ជាមួយការសម្រេចឱ្យរៀបចំការ-ប្រកួតស៊ីហ្គេម លើកទី៣២ ឆ្នាំ២០២៣ ជាលើកដំបូងនេះ កម្ពុជា បានឈានដល់ការបង្កើតឱ្យមាននូវគណៈកម្មាធិ-ការជាតិរៀបចំការប្រកួតកីឡាអាស៊ី-អាគ្នេយ៍ លើកទី៣២ ឆ្នាំ២០២៣ (CAMSOC) កាលពីឆ្នាំ២០១៦ ដើម្បីទទួលខុសត្រូវរួម និងរៀបចំផែនការមេឆ្ពោះទៅស៊ីហ្គេមនេះ។

ជាមួយគ្នានោះ កម្ពុជា បានបង្កើតឱ្យមាននូវហេដ្ឋារចនាសម្ព័ន្ធកីឡាទីលាន ព្រមទាំងជួសជុលទីលាននៅតាមបណ្តារាជធានី-ខេត្ត ដើម្បីបម្រើដល់ការរៀបចំស៊ីហ្គេមនេះ ហើយវិមានពហុកីឡដ្ឋានជាតិមរតកតេជោ ដែលត្រូវបានសាងសង់ឡើង អស់ប្រមាណ១៥០លានដុល្លារ ជាជំនួយឥតសំណងរបស់មិត្តចិននោះ ជាទីតាំងដ៏សំខាន់ សម្រាប់ទ្រទ្រង់ដល់ការ-ប្រកួតនេះ ព្រមទាំងសម្រាប់រៀបចំពិធីបើក-បិទ ស៊ីហ្គេម ឆ្នាំ២០២៣ នេះតែម្តង។

ទន្ទឹមនឹងនេះ ធនធានអត្តពលិក និងមន្ត្រីបច្ចេកទេស នៅលើប្រភេទកីឡានីមួយៗក៏ត្រូវបានបណ្តុះបណ្តាលឱ្យកាន់តែមានគុណភាពផងដែរ ដើម្បីសម្រេចទិសដៅឆ្ពោះទៅកាន់ការ-ប្រកួតស៊ីហ្គេម ឆ្នាំ២០២៣ ដែលព្រឹត្តិការណ៍នេះ កម្ពុជា បានរង់ចាំអស់រយៈពេល៦៤ឆ្នាំហើយ។

លោកឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ទៀ បាញ់ ជាប្រធាន CAMSOC បានថ្លែងនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាសហព័ន្ធកីឡា-អាស៊ីអាគ្នេយ៍ ក្នុងនាមជាម្ចាស់ផ្ទះ នៅខេត្តសៀមរាប កាលពីថ្ងៃទី៩ ខែមេសា ឆ្នាំ២០២២ ថា៖ «ពេលនេះ ជាឱកាសដ៏វិសេសវិសាលមួយ ដែលខ្ញុំសូមរំឭកឡើងវិញថា កម្ពុជា បានរង់ចាំរយៈពេល ៦៤ឆ្នាំ ទើបអាចមានលទ្ធភាពទទួលធ្វើជាម្ចាស់ផ្ទះស៊ីហ្គេមដ៏ធំនេះ ក្រោមគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ និងប៊ិនប្រសប់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ស្របពេលដែលកម្ពុជាកំពុងរស់នៅក្នុងដំបូលសន្តិភាព និងកិច្ចប្រឹងប្រែងស្តារស្ថានភាពសង្គមសេដ្ឋកិច្ច និងលើកស្ទួយនូវរិបូលភាពសម្រាប់ទាំងអស់គ្នា ក្រោយពីវិបត្តិជំងឺកូវីដ១៩»។

លោកបានបន្ថែមថា៖ «បច្ចុប្បន្នរាជរដ្ឋាភិបាល បានយកចិត្តទុកដាក់-ខ្ពស់ ក្នុងការអភិវឌ្ឍវិស័យកីឡា និងចលនាអូឡាំពិក ក្នុងដំណើរឆ្ពោះទៅរៀបចំធ្វើម្ចាស់ផ្ទះការប្រកួតស៊ីហ្គេមឆ្នាំ២០២៣ ឱ្យទទួលបានកិត្តិយសសេចក្តីថ្លៃថ្នូរ និងជោគជ័យ។ រាជរដ្ឋាភិបាល បានវិនិយោគធនធាន ថវិកា កម្លាំងកាយចិត្ត ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធកីឡា ទីលាន ប្រកួតកីឡាពិសេសពហុកីឡដ្ឋានជាតិ ដើម្បីបម្រើឱ្យការប្រកួតជាអន្តរជាតិផង និងសម្រាប់ការហ្វឹកហ្វឺនជំនាញកីឡាគ្រប់ប្រភេទផង»។

ប្រធាន CAMSOC រូបនេះ បានឱ្យដឹងទៀតថា ការអភិវឌ្ឍធនធានមនុស្សជំនាញកីឡា គឺកីឡាករ កីឡាការិនី គ្រូបង្វឹក មន្ត្រីបច្ចេកទេសកីឡា ក៏ត្រូវបានដាក់ចេញនូវការឧបត្ថម្ភគាំទ្រ និងផ្តត់ផ្តង់ដល់ក្រុមជម្រើសជាតិ ដើម្បីបំប៉នការហាត់ ហ្វឹកហ្វឺន ឈានទៅរកគុណផល កីឡាកម្រិតខ្ពស់ និងស្វែង-រកកម្រិតស្តង់ដាបច្ចេកទេសកីឡាក្នុងតំបន់ និងលើឆាកអន្តរជាតិ។

ជាមួយគ្នានេះ កម្ពុជា ក៏បានទទួលជោគជ័យផងដែរ ក្នុងការដាក់ប្រភេទកីឡាប្រពៃណី «គុនល្បុក្កតោ» ទៅក្នុងការប្រកួតស៊ីហ្គេម ឆ្នាំ២០២៣នេះ នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាកីឡាអាស៊ី-អាគ្នេយ៍ កាលពីខែមេសា ឆ្នាំ២០២២ ហើយអង្គប្រជុំ ក៏បានឯកភាពដាក់ប្រភេទកីឡាចំនួន៣៩ទៀតផងដែរ ដែលធ្វើឱ្យការប្រកួតស៊ីហ្គេម ឆ្នាំ២០២៣ នៅកម្ពុជា មានចំនួនប្រភេទកីឡាច្រើនបំផុត។

លោក វ៉ាត់ ចំរើន អគ្គលេខាធិការ CAMSOC បានថ្លែងថា៖ «ការដាក់-គុនល្បុក្កតោ ចូលទៅក្នុងការប្រកួតស៊ីហ្គេម ឆ្នាំ២០២៣ វាជាគោលបំណងរបស់យើងយូរមកហើយ ហើយវាជាកិត្តិយសរបស់យើង ក្នុងនាមជាម្ចាស់-ផ្ទះ ដែលបានដាក់ក្បាច់គុន ជាប្រពៃណីវប្បធម៌របស់យើង ចូលទៅក្នុងស៊ីហ្គេម អ៊ីចឹងផែនការរបស់យើងទទួលបានជោគជ័យ ដោយសារប្រទេសទាំងអស់បានគាំទ្រ ដាក់ឱ្យបញ្ចូលជាផ្លូវការ កាលពីព្រឹកមិញនេះ ហេតុនេះវាជាមហាកិត្តិយសមួយហើយ សម្រាប់យើង»។

ទន្ទឹមនឹងនេះ ថ្នាក់ដឹកនាំ CAMSOC ក៏បានប្រកាសប្រាប់ប្រជាជន នៅទូទាំងប្រទេសកម្ពុជា ពីការឈានមកដល់របស់ស៊ីហ្គេមនៅកម្ពុជាផងដែរ នៅពេលប្រតិភូកីឡាកម្ពុជា ដឹកនាំដោយលោក ទៀ បាញ់ ផ្ទាល់បានរៀបចំដង្ហែទង់ស៊ីហ្គេម និងម្ចាស់ជយលាភីមេដាយមាស ពីការប្រកួតស៊ីហ្គេម នៅប្រទេសវៀតណាម មកដល់មាតុ-ប្រទេស កាលពីថ្ងៃទី២៤ ខែឧសភា កន្លងមកនេះ។

នៅក្នុងឱកាសនោះ លោក ទៀ បាញ់ បានថ្លែងថា៖«ថ្ងៃនេះប្រជាពលរដ្ឋទូទាំងប្រទេស ពិតជាមានសោមនស្ស-រីករាយ និងមោទនភាពដែលព្រះរាជា-ណាចក្រកម្ពុជា បានបើកទំព័រប្រវត្តិ-សាស្ត្រថ្មីមួយទៀត ទស្សនទានការ-ទូតកីឡា និងកិត្យានុភាពជាតិ ក្នុងការ-នាំមកនូវទង់សហព័ន្ធកីឡាស៊ីហ្គេម លើកទី៣២ នៅកម្ពុជា។ ហេតុនេះ សូមបងប្អូនជនរួមជាតិ ដែលរស់នៅក្នុង និងក្រៅប្រទេស សូមត្រៀមរៀបចំគ្រប់លក្ខណសម្បត្តិ ក្នុងនាមម្ចាស់ផ្ទះ ដោយរង់ចាំទទួលស្វាគមន៍ប្រតិភូកីឡាអាស៊ីអាគ្នេយ៍ និងភ្ញៀវអន្តរជាតិ មកពីគ្រប់ទិសទីជុំវិញពិភពលោក ដើម្បីទទួលយកនូវស្នាមញញឹម រួសរាយរាក់ទាក់ ជាមួយនឹងតំរិយាបថស្លូតបូត សុភាពរាបសា ថ្លៃថ្នូររបស់ប្រជាជនកម្ពុជាយើង ដែលកំពុងរស់នៅក្នុងសន្តិភាពពេញលេញ និងការអភិវឌ្ឍលើគ្រប់វិស័យ»៕ ■